ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅរោងចក្រ ត្រាយអាំហ្វិន ដ្រេហ្គុន (ខេមបូឌា) ឯ.ក

TRIUMPHANT DRAGON (CAMBODIA) CO., LTD.

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតទាំងអស់នៃរោងចក្រ ត្រាយអាំហ្វិន ដ្រេហ្គុន (ខេមបូឌា) ឯ.ក ដែលមានអាសយដ្ឋានស្ថិតនៅភូមិខ្នារទង់ ឃុំកុមាររាជា ស្រុកបាទី ខេត្តតាកែវ និងសាខាសហគ្រាសស្ថិតនៅភូមិធ្លក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឱ្យបានជ្រាបថា នៅព្រឹកថ្ងៃចន្ទ ទី២៦ ខែមករា ឆ្នាំ២០២៦ មានករណីបងប្អូនកម្មករនិយោជិតនៃរោងចក្រខាងលើ បានធ្វើកូដកម្មទាមទារឱ្យរោងចក្រអនុវត្តនូវលក្ខខណ្ឌការងារមួយចំនួនក្នុងនោះ ទាមទារឱ្យម្ចាស់ ឬនាយកនៃរោងចក្រទូទាត់ការឈប់សម្រាកប្រចាំឆ្នាំរបស់ខ្លួនជាប្រាក់។

យោងតាមកថាខណ្ឌទី៣ មាត្រា១៦៧ នៃច្បាប់ស្តីពីការងារ ចែងថា "អនុសញ្ញាណាដែលមានគ្រោងឱ្យប្រាក់បំណាច់ដើម្បីទូទាត់សម្រាប់ជួសការឈប់សម្រាកព្រមទាំងការព្រមព្រៀងស្តីពីការបោះបង់ ឬមិនព្រមប្រើសិទ្ធិឈប់សម្រាកប្រចាំឆ្នាំត្រូវទុកជាមោឃៈ ហើយគ្មានហេតុផលអ្វីទាំងអស់" មានន័យថា ការឈប់សម្រាកប្រចាំឆ្នាំដែលមានប្រាក់ឈ្នួលមិនអាចទូទាត់ជាប្រាក់នៅពេលដែលកម្មករនិយោជិតកំពុងធ្វើការនៅក្នុងសហគ្រាស ក្រុមហ៊ុន រោងចក្របានទេ តែអាចទូទាត់ជាប្រាក់បាននៅពេលរំលាយកិច្ចសន្យាការងារ (បញ្ឈប់ពីការងារ)។ ការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ថ្ងៃ ក្នុងមួយឆ្នាំ គឺជាពេលវេលាមួយដែលតម្រូវឱ្យកម្មករនិយោជិតធ្វើការឈប់សម្រាកដើម្បីថែទាំសុខភាពទាំងផ្លូវកាយនិងផ្លូវចិត្ត។

ជាមួយគ្នានេះ ក្រសួងក៏សូមអំពាវនាវដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងបងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាចូលរួមដោះស្រាយដោយស្មារតីនៃការយោគយល់គ្នា សន្តិវិធី និងចៀសវាងការយកជម្រើសធ្វើការតវ៉ា ឬកូដកម្មដែលមិនមានចែងក្នុងច្បាប់ជាអាទិ៍ ការបិទផ្លូវសាធារណៈ នាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ដែលសកម្មភាពបែបនេះគឺជាការប្រព្រឹត្តល្មើសច្បាប់ស្តីពីការងារផង និងជាបទល្មើសព្រហ្មទណ្ឌផងដែរ។

អាស្រ័យហេតុនេះ សូមសាធារណជន និងបងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៨កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩